**នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង**

**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**


ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 23-Jun-2011, 09:59
CMS/CFO: Sann Rada


សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អវតក-អជសង

ភាគីដាក់ឯកសារ: មេធាវីការពារក្តីរបស់លោក អៀង សារី

ដាក់ជូន: អង្គជំនុំជម្រះសាលាដំបូង

ភាសាដើម: អង់គ្លេស

កាលបរិច្ឆេទឯកសារ: ថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០១១

**<u>ចំណាត់ថ្នាក់ឯកសារ</u>**

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ

ចំណាត់ថ្នាក់ឯកសារដោយ កសចស ឬ អង្គជំនុំជម្រះ: **សាធារណៈ/Public**

ស្ថានភាពចំណាត់ថ្នាក់ឯកសារ:

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់បណ្តោះអាសន្ន:

ឈ្មោះមន្ត្រីកត់ត្រា:

ហត្ថលេខា:

---

**សំណើរបស់ លោក អៀង សារី សុំអនុញ្ញាតឲ្យធ្វើការឆ្លើយតប និង ការឆ្លើយតបទៅនឹងចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅលើ “ញត្តិរបស់ អៀង សារី សុំឲ្យដាក់បញ្ចូលប្រព័ន្ធគ្រប់គ្រងសំណុំរឿង (CaseMap) របស់ ក.ស.ច.ស នៅក្នុងសំណុំរឿង”**

---

<u>ដាក់ដោយ</u>៖

**សហមេធាវី៖**

លោក អាង ឧត្តម

លោក Michael G. KARNAVAS

<u>ផ្ញើជូន</u>៖

**អង្គជំនុំជម្រះសាលាដំបូង**

ចៅក្រម **និល ណុន** ជាប្រធាន

ចៅក្រម **ឌូ មណី**

ចៅក្រម **យ៉ា សុខន**

ចៅក្រម Silvia CARTWRIGHT

ចៅក្រម Jean-Marc LAVERGNE

ចៅក្រមបម្រុង **យូរ ឧត្តរា**

ចៅក្រមបម្រុង Claudia FENZ

<u>ផ្ញើជូន</u>៖

**សហព្រះរាជអាជ្ញា**

លោកស្រី ជា លាង

លោក Andrew CAYLEY

**ក្រុមមេធាវីការពារក្តីទាំងអស់**

**ដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់**

## សំណើសុំអនុញ្ញាតធ្វើការឆ្លើយតប

លោក **អៀង សារី** តាមរយៈសហមេធាវីរបស់ខ្លួន (“មេធាវីការពារក្ដី”) សូមស្នើសុំអង្គជំនុំជម្រះសាលាដំបូងអនុញ្ញាតឲ្យធ្វើការឆ្លើយតបទៅនឹងចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹង “ញត្តិរបស់ អៀង សារី សុំឲ្យដាក់បញ្ចូលប្រព័ន្ធគ្រប់គ្រងសំណុំរឿង (CaseMap) របស់ ក.ស.ច.ស ទៅក្នុងសំណុំរឿង” (“ការឆ្លើយតប”)[១]។ ការបកស្រាយមិនបានត្រឹមត្រូវនូវអង្គច្បាប់ និងទឡ្ហីករណ៍នានា ដែលបានលើកឡើងនៅក្នុងញត្តិរបស់លោក អៀង សារី សុំឲ្យដាក់បញ្ចូលប្រព័ន្ធគ្រប់គ្រងសំណុំរឿងរបស់ ក.ស.ច.ស ទៅក្នុងសំណុំរឿង (“ញត្តិ”)[២] បង្កើតបានជាកាលៈទេសៈចាំបាច់បង្ខំឲ្យមានការឆ្លើយតប ព្រោះបើមិនមានការឆ្លើយតបទេ អាចនឹងនាំឲ្យអង្គជំនុំជម្រះសាលាដំបូងចេញសេចក្ដីសម្រេចមួយដោយមិនត្រឹមត្រូវ ដោយផ្អែកលើការវាយតម្លៃមិនត្រឹមត្រូវចំពោះច្បាប់ និងនីតិវិធីជាធរមាននៅ អ.វ.ត.ក។ ការឆ្លើយតបនេះជាការចាំបាច់ ដោយសារ ក.ស.ព អនុវត្តច្បាប់មិនបានត្រឹមត្រូវ និងបកស្រាយមិនបានត្រឹមត្រូវនូវទឡ្ហីករណ៍នានាដែលបានធ្វើឡើងនៅក្នុងញត្តិនោះ។ ក.ស.ព ខកខានមិនបានផ្ដល់នូវសំអាងហេតុរឹងមាំ ឬឯកសារយោងផ្នែកច្បាប់ដែលពាក់ព័ន្ធ ដើម្បីគាំទ្រដល់ទឡ្ហីករណ៍របស់ខ្លួនឡើយ។ ដើម្បីសន្សំសំចៃធនធានតុលាការ និងដើម្បីឲ្យបានឆាប់រហ័ស ការឆ្លើយតបរបស់លោក អៀង សារី ត្រូវបានភ្ជាប់ជាមួយស្រាប់ ក្នុងករណីដែលអង្គជំនុំជម្រះសាលាដំបូងផ្ដល់ឱកាសឲ្យធ្វើការឆ្លើយតបបាន។

## ការឆ្លើយតប

១. នៅក្នុងកថាខណ្ឌ១ ក.ស.ព បានលើកឡើងដោយភាន់ច្រឡំថា “សំណើសុំរបស់មេធាវីការពារក្ដី [sic] ផ្អែកលើមូលដ្ឋានចំនួនបី”។ តាមពិត ញត្តិនោះលើកឡើងនូវមូលដ្ឋានចំនួនបួន[៣]។

---

[១] ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹង “ញត្តិរបស់ អៀង សារី សុំឲ្យដាក់បញ្ចូលប្រព័ន្ធគ្រប់គ្រងសំណុំរឿង (CaseMap) របស់ ក.ស.ច.ស ទៅក្នុងសំណុំរឿង” ចុះថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០១០ ឯកសារលេខ E91/1។

[២] ញត្តិរបស់ អៀង សារី សុំឲ្យដាក់បញ្ចូលប្រព័ន្ធគ្រប់គ្រងសំណុំរឿង (CaseMap) របស់ ក.ស.ច.ស ទៅក្នុងសំណុំរឿង ចុះថ្ងៃទី ៣ ខែ មិថុនា ឆ្នាំ ២០១០ ឯកសារលេខ E91។

[៣] **ក.**មេធាវីការពារក្ដីមានសិទ្ធិទទួលបានប្រព័ន្ធគ្រប់គ្រងសំណុំរឿងរបស់ ក.ស.ច.ស ពីអង្គជំនុំជម្រះសាលាដំបូង ពីព្រោះជាការសមស្រប ប្រព័ន្ធគ្រប់គ្រងសំណុំរឿងត្រូវបានគេចាត់ទុកថាជាផ្នែកនៃសំណុំរឿង; **ខ.**ការដាក់បញ្ចូលប្រព័ន្ធគ្រប់គ្រងសំណុំរឿងរបស់ ក.ស.ច.ស ទៅក្នុងសំណុំរឿង នឹងការពារសិទ្ធិរបស់ អៀង សារី ក្នុងការទទួលបានការជំនុំជម្រះប្រកបដោយ

២. ពីកថាខណ្ឌ២ ដល់៤ ក.ស.ព គ្រាន់តែបង្ហាញទឡ្ហីករណ៍របស់ខ្លួន និងសារតារ[៤] តែប៉ុណ្ណោះ។

៣. នៅក្នុងកថាខណ្ឌ៥ ក.ស.ព បានអះអាងថា និយមន័យនៃពាក្យថា "សំណុំរឿង" នៅក្នុងវិធានផ្ទៃក្នុង អ.វ.ត.ក ("វិធាន") គឺថាជា "កំណត់ហេតុនៃកិច្ចស៊ើបសួរ *(procés verbaux)*" ដែល "មិនមែន (និង*មិនអាច*) រួមបញ្ចូល<u>អ្វីៗគ្រប់បែបយ៉ាង [sic] ដែលបានសរសេរដោយ ក.ស.ច.ស នៅក្នុងអំឡុងពេលនៃកិច្ចស៊ើបសួរ</u> ដូចដែលមេធាវីការពារក្តីបានអះអាងនោះទេ"[៥]។ ការអះអាងបែបនេះជាការលើកឡើងខុសអំពីទឡ្ហីករណ៍របស់មេធាវីការពារក្តី។ មេធាវីការពារក្តីបានលើកឡើងថា "ជា*កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចស៊ើបសួរ* សំណុំរឿងមានឯកសារពាក់ព័ន្ធទាំងអស់ រួមទាំងកំណត់ហេតុនៃការស្តាប់ចម្លើយ សារណា សេចក្តីសម្រេច និងការវិភាគ ដែលទាក់ទងនឹងការកំណត់នូវការពិតនៃអង្គហេតុទាំងឡាយ ដែលត្រូវបានចោទប្រកាន់នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួររបស់ ក.ស.ព"[៦]។ មេធាវីការពារក្តីសូមលើកឡើងថា មិនត្រឹមតែប្រព័ន្ធគ្រប់គ្រងសំណុំរឿងរបស់ ក.ស.ច.ស ប៉ុណ្ណោះទេ ដែលត្រូវបានចាត់ទុកជា "កំណត់ហេតុជាលាយលក្ខណ៍អក្សរ" ក៏ប៉ុន្តែកំណត់ហេតុនេះក៏អាចជាកំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធីយថាភូតដ៏ពិស្តារ *បំផុត*[៧] ដែរ។

---

យុត្តិធម៌ ដែលត្រូវជំនុំជម្រះឲ្យបានឆាប់រហ័ស និង មានពេលវេលា និងសម្ភារៈរូបវន្តគ្រប់គ្រាន់ សម្រាប់រៀបចំការពារខ្លួន; **គ.** ការដាក់បញ្ចូលប្រព័ន្ធគ្រប់គ្រងសំណុំរឿងរបស់ ក.ស.ច.ស ទៅក្នុងសំណុំរឿង នឹងការពារសិទ្ធិរបស់ អៀង សារី ក្នុងការមានពេលវេលា និងសម្ភារៈរូបវន្តគ្រប់គ្រាន់ដើម្បីរៀបចំការពារខ្លួន; និង **ឃ.**ប្រសិនបើប្រព័ន្ធគ្រប់គ្រងសំណុំរឿងរបស់ ក.ស.ច.ស ត្រូវបានផ្តល់ទៅឲ្យអង្គជំនុំជម្រះសាលាដំបូង នេះបញ្ជាក់ថា ប្រព័ន្ធគ្រប់គ្រងសំណុំរឿងរបស់ ក.ស.ច.ស គឺជាផ្នែកនៃសំណុំរឿង ហើយភាគីមានសិទ្ធិពិនិត្យមើលបាន។

[៤] ទោះជាយ៉ាងណាក្តី មេធាវីការពារក្តីកត់សម្គាល់ឃើញថា ក.ស.ច.ស មិនបានព្រមានមេធាវីការពារក្តីពីការមិនយកមកអនុវត្តនូវនីតិវិធីដែលមានជាធរមានក្នុងកិច្ចស៊ើបសួរ ដោយការស្នើសុំប្រព័ន្ធគ្រប់គ្រងសំណុំរឿងរបស់ ក.ស.ច.ស នោះទេ។ ដីកាសម្រេចធ្វើការព្រមានដោយអនុវត្តតាមវិធាន៣៨ ចុះថ្ងៃទី ២៥ ខែ កុម្ភៈ ឆ្នាំ ២០១០ ឯកសារលេខ D367។

[៥] គូសបញ្ជាក់បន្ថែម។

[៦] ញត្តិ, កថាខណ្ឌ ៥។

[៧] សម្រាប់សំអាងហេតុនេះដែលមេធាវីការពារក្តីបានកត់សម្គាល់នៅក្នុងញត្តិដែលថា "យើងអាចយល់បានថា អង្គជំនុំជម្រះសាលាដំបូងពឹងផ្អែកលើប្រព័ន្ធមួយនេះ ឬយ៉ាងហោចណាស់ក៏នឹងប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងសំណុំរឿងដែលបង្កើតឡើងដោយ ក.ស.ច.ស ដោយហេតុថា ប្រព័ន្ធគ្រប់គ្រងសំណុំរឿងរបស់ ក.ស.ច.ស អាចជាឯកសារដើមដូចជា *កំណត់ហេតុជាលាយ*

៤. ពីកថាខណ្ឌ៦ ដល់៨ ក.ស.ព អះអាងថា មាត្រា២៤០ និង២៤២ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា ("CPC") និងការអត្ថាធិប្បាយទៅលើនីតិវិធីព្រហ្មទណ្ឌបារាំង លើកឡើងថា "កំណត់ហេតុជាលាយលក្ខណ៍អក្សរត្រូវបានចាត់ទុកជាឯកសារប្រភេទជាក់លាក់មួយ មិនមែនគ្រប់ឯកសារដែលសរសេរឡើងដោយ ស.ច.ស ឬ បុគ្គលិករបស់ខ្លួនប៉ុណ្ណោះទេ"[៨]។ ទទ្បីករណ៍របស់ ក.ស.ព បានផ្ដល់អាទិភាពលើទម្រង់ជាជាងខ្លឹមសារ និងមិនបានគោរពចំពោះលក្ខណៈពិសេសរបស់ អ.វ.ត.ក ទេ[៩]៖ ជាការសមហេតុសមផលដែលត្រូវសន្មតថា ប្រព័ន្ធគ្រប់គ្រងសំណុំរឿងត្រូវបានប្រើប្រាស់ដោយ ក.ស.ច.ស ដើម្បីបង្កើតជា*កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចស៊ើបសួរ*សម្រាប់ការសួរចម្លើយ ការស្តាប់ចម្លើយ និងការសួរតទល់នីមួយៗ (ដូចដែលមានចែងក្នុងមាត្រា២៤២ នៃ CPC)។ នៅក្នុងបរិបទនេះ លក្ខខណ្ឌតម្រូវតាមផ្លូវច្បាប់ក្នុងមាត្រា២៤០ នៃ CPC មិនគួរមានសារសំខាន់ជាងការចែងថា *កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចស៊ើបសួរ* នឹងត្រូវកត់ត្រានៅក្នុងប្រព័ន្ធគ្រប់គ្រងសំណុំរឿងរបស់ ក.ស.ច.ស ហើយហេតុនេះកំណត់ហេតុទាំងនេះត្រូវចាត់ទុកយ៉ាងសមរម្យថាជាផ្នែកមួយនៃសំណុំរឿង។

៥. នៅក្នុងកថាខណ្ឌ៩ ក.ស.ព អះអាងថា "មានភាពខុសគ្នាយ៉ាងច្បាស់រវាង*ផលិតផល* នៃកិច្ចស៊ើបសួរព្រហ្មទណ្ឌ ដូចជាភស្តុតាងថាតើជាភស្តុតាងដោះបន្ទុក ឬដាក់បន្ទុក និងការចោទប្រកាន់ដែលគេត្រូវផ្តល់ឲ្យមេធាវីការពារក្តី និងឯកសារការងារផ្ទៃក្នុងទាក់ទងនឹងកិច្ចស៊ើបសួរដែលត្រូវការពារមិនឲ្យលាតត្រដាង"។ ការអះអាងបែបនេះជាការយល់ខុសពីលក្ខណៈនៃប្រព័ន្ធដែលជជែកសួរដេញដោលដោយចៅក្រម។ កសព លើកឡើងពីភាពចាំបាច់ដែលត្រូវអនុវត្តគោលការណ៍បុព្វសិទ្ធិ

---

*លក្ខណ៍អក្សរនៃកិច្ចស៊ើបសួរ* ដែលជាមូលដ្ឋាននៃដីកាដំណោះស្រាយ" ហើយថា ការធ្វើបែបនេះ "អាចឲ្យយើងសន្សំសំចៃធនធានតុលាការ និងបញ្ចៀសភាពច្រំដែល"។ *ដូចដើងទំព័រខាងលើ* កថាខណ្ឌ ១៩។

[៨] ចម្លើយតប, កថាខណ្ឌ៦។

[៩] វិធាន២១ តម្រូវឲ្យពិចារណាទៅលើ "លក្ខណៈពិសេស" របស់ អ.វ.ត.ក នៅពេលបកស្រាយលិខិតុបករណ៍របស់ អ.វ.ត.ក ក្នុងលក្ខណៈដើម្បីការពារដល់សិទ្ធិរបស់លោក អៀង សារី និងដើម្បីធានានូវភាពច្បាស់លាស់ និងតម្លាភាពតាមផ្លូវច្បាប់នៅក្នុងកិច្ចដំណើរការនីតិវិធី។ អ.វ.ត.ក មានលក្ខណៈពិសេសដែលថា ស្ថាប័នមានកាតព្វកិច្ចជំនុំជម្រះទោសនូវរឿងក្តីនៃបទឧក្រិដ្ឋសង្គ្រាមដែលមានទំហំធំ និងស្មុគស្មាញ ខណៈដែលដំណាក់កាលនៃកិច្ចស៊ើបសួរត្រូវបានធ្វើឡើងក្រោមការគ្រប់គ្រងផ្តាច់មុខរបស់ ក.ស.ច.ស។ *សូមមើល* ញត្តិ, កថាខណ្ឌ១២-១៤។

និងការលាតត្រដាងរបស់ប្រព័ន្ធខំមិនឡ ដែលបង្ហាញសញ្ញាណថា ភាគីជាអ្នកទទួលខុសត្រូវក្នុងការបើកកិច្ចស៊ើបសួរ។

៦. នៅក្នុងកថាខណ្ឌ១០ ក.ស.ព អះអាងថា ““របាយការណ៍ អនុស្សរណៈ ឬឯកសារផ្ទៃក្នុងដទៃទៀត ដែលបានរៀបចំដោយ<u>ភាគីណាមួយ អ្នកជំនួយការ ឬអ្នកតំណាងរបស់ភាគីនោះ</u> ទាក់ទិននឹងកិច្ចស៊ើបសួរ ឬការត្រៀមរៀបចំករណីនោះ មិនមែនជាកម្មវត្ថុនៃការដាក់បង្ហាញ ឬការជូនដំណឹងតាម”” វិធាននីតិវិធី និងភស្តុតាងនៃតុលាការ ICTY និង ICTR[១០]។ ជាថ្មីម្តងទៀត ភាពខុសគ្នាសាមញ្ញ តែជាមូលដ្ឋាន គឺថា នៅតុលាការ ICTY និង ICTR <u>ភាគីជាអ្នកទទួលខុសត្រូវក្នុងការបើកកិច្ចស៊ើបសួររបស់ខ្លួន</u>[១១]៖ ទាំងកិច្ចដំណើរការនីតិវិធីដោយគូភាគី ដោយភាគីនីមួយៗត្រូវបង្កើតសំណុំរឿងក្តីដោយខ្លួនឯង[១២]។ ដំណើរការស៊ើបសួរដែលការពារដោយវិធានទាំងនេះ មិនមាននៅក្នុងប្រព័ន្ធដែលជជែកសួរដេញដោលចៅក្រមផ្អែកលើនីតិវិធីរបស់បារាំងនោះទេ។ ក.ស.ព មិនអាចជ្រើសរើសយកផ្លូវទាំងពីរបានទេ៖ ក.ស.ព មិនអាចលើកជាទឡ្ហីករណ៍ថា អ.វ.ត.ក មាននីតិវិធីដែលស្ថិតក្នុងប្រព័ន្ធដែលជជែកសួរដេញដោលដោយចៅក្រម ប៉ុន្តែនៅពេលងាយស្រួល បែរ

---

[១០] គូសបញ្ជាក់បន្ថែម។

[១១] *ប្រៀបធៀប* អ.វ.ត.ក ដែលកិច្ចស៊ើបសួរត្រូវបានដំណើរការ*ផ្តាច់មុខ*ដោយ ក.ស.ច.ស។ *សូមមើល* ដីកាដែលចេញការព្រមានប្រាប់តាមវិធាន៣៨ ចុះថ្ងៃទី ២៥ ខែ កុម្ភៈ ឆ្នាំ ២០១០ ឯកសារលេខ D367។ *សូមមើលផងដែរ* ចម្លើយតបទៅនឹងលិខិតរបស់លោក ចុះថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ២00៧ ពាក់ព័ន្ធនឹងការបើកកិច្ចស៊ើបសួរ ឯកសារលេខ A110/I ទំព័រ២។

[១២] *សូមមើល* ប្រតិចារិតនៃសវនាការ៖ កិច្ចប្រជុំរៀបចំសវនាការ ការប្រជុំដោយសម្ងាត់ ថ្ងៃទី ៥ ខែ មេសា ឆ្នាំ ២០១១ ទំព័រ ១១៤។ សហព្រះរាជអាជ្ញារងបរទេសបានផ្តល់ការសង្កេតរបស់ខ្លួនទាក់ទិននឹងកាតព្វកិច្ចក្នុងផ្តល់នូវបញ្ជីឯកសារ អនុលោមតាមវិធាន៨0 ថា៖ “ដូចដែលលោក លោកស្រីចៅក្រមបានជ្រាបហើយ ទាក់ទងទៅនឹងតុលាការយូហ្គោស្លាវី ហើយនិងរវ៉ាន់ដា ផ្អែកខ្លាំងទៅលើច្បាប់ខំមិនឡ ប៉ុន្តែលក្ខណៈលាយឡំនឹងស៊ីវិលឡ”។ *ប្រៀបធៀប* ជំហររបស់មេធាវីការពារក្តីលើគំរូនៃនីតិវិធីសវនាការដែលយកមកអនុវត្តនៅ អ.វ.ត.ក។ សំណើរបស់ អៀង សារី សុំឱ្យអង្គជំនុំជម្រះសាលាដំបូងធ្វើការជំនុំជម្រះលើសំណុំរឿងលេខ00២ ដោយអនុវត្តតាមវិសោធនកម្មនីតិវិធីដែលបានស្នើសុំ និងសំណើសុំផ្អាកជាបន្ទាន់លើដីកាបង្គាប់ដាក់សម្ភារៈសម្រាប់រៀបចំសវនាការ ថ្ងៃទី ២៨ ខែ មករា ឆ្នាំ ២០១១ ឯកសារលេខ E9/3 ដែលក្នុងនោះមេធាវីការពារក្តីបានលើកឡើងជាទឡ្ហីករណ៍ថា ដោយការអនុម័តនូវគំរូនីតិវិធីដែលជជែកសួរដេញដោលដោយគូភាគីនៅក្នុងវិធាននោះ អ.វ.ត.ក “ទំនងជាមានចេតនាមិនអនុវត្តតាមទិដ្ឋភាពមួយចំនួននៅក្នុងនីតិវិធីព្រហ្មទណ្ឌនៃប្រព័ន្ធដែលជជែកសួរដេញដោលដោយចៅក្រម និងធាតុផ្សំនានានៅក្នុងនីតិវិធីនៃប្រព័ន្ធដែលជជែកសួរដេញដោលដោយភាគី ស្រដៀងគ្នាទៅនឹងនីតិវិធីដែលត្រូវបានអនុម័តដោយតុលាការព្រហ្មទណ្ឌអន្តរជាតិ (“ICC”) និង តុលាការព្រហ្មទណ្ឌមិនអចិន្ត្រៃយ៍ដទៃទៀត”។

ជាពឹងផ្អែកលើគោលការណ៍ប្រព័ន្ធខំមិនឡ ដែលផ្ទុយពីនីតិវិធីក្នុងប្រព័ន្ធស៊ីវិលឡដែលខ្លួននៅតែទទូចឲ្យយកមកអនុវត្តនោះ។

៧. នៅក្នុងកថាខណ្ឌ១១ ក.ស.ព អះអាងថា ““ទ្រឹស្តីស្នាដៃផលិត” ឬ គោលការណ៍ស្តីពី “បុព្វសិទ្ធិនៅក្នុងរឿងក្តីវិវាទ” នៃយុត្តាធិការក្នុងស្រុកនានាបានគាំទ្រដល់ទស្សនៈផ្ទុយរបស់ខ្លួនក្នុងកថាខណ្ឌ១២ ដែលថា “ប្រព័ន្ធគ្រប់គ្រងសំណុំរឿងរបស់ ក.ស.ច.ស គឺ ... “ឯកសារ ឬការប្រាស្រ័យទាក់ទងគ្នាដែលមានបុព្វសិទ្ធិ” មួយ”។ វិធាន និងយុត្តាធិការរបស់តុលាការក្នុងស្រុកដែល ក.ស.ព បានដកស្រង់ មកពីយុត្តាធិការនៅក្នុងប្រព័ន្ធខំមិនឡទាំងអស់[១៣] ដែលភាគីជាអ្នកទទួលខុសត្រូវក្នុងការបើកកិច្ចស៊ើបសួរដោយខ្លួនឯង។ ក.ស.ច.ស មិនមានបុព្វសិទ្ធិនៅក្នុងរឿងក្តីវិវាទ “ស្នាដៃផលិត” ទេ ដោយសារ ក.ស.ច.ស មិនមែនជាភាគីនៅក្នុងរឿងក្តីវិវាទ។

៨. នៅក្នុងកថាខណ្ឌ១២ ក.ស.ព អះអាងថា “មេធាវីការពារក្តីមិនបានផ្តល់ភស្តុតាងថា ប្រព័ន្ធគ្រប់គ្រងសំណុំរឿងរបស់ ក.ស.ច.ស ត្រូវបានផ្តល់ឲ្យទៅអង្គជំនុំជម្រះសាលាដំបូងនោះឡើយ ហេតុដូចនេះគ្មានភស្តុតាងណាដែលបង្ហាញថា ក.ស.ច.ស បានលះបង់ចោលនូវបុព្វសិទ្ធិរបស់ខ្លួនលើព័ត៌មានទាំងនេះទេ”។ ក.ស.ព ទំនងជាទទួលស្គាល់ថា ប្រសិនបើប្រព័ន្ធគ្រប់គ្រងសំណុំរឿងរបស់ ក.ស.ច.ស ត្រូវបានផ្តល់ឲ្យអង្គជំនុំជម្រះសាលាដំបូងនោះ ក.ស.ច.ស នឹងបាន “លះបង់ចោលនូវបុព្វសិទ្ធិរបស់ខ្លួន” ឬ “បង្ហាញពីចេតនាដែលថា ប្រព័ន្ធគ្រប់គ្រងសំណុំរឿងរបស់ខ្លួនមិនគួរត្រូវបានចាត់ទុកថាជា “ឯកសារសម្ងាត់ផ្ទៃក្នុង” ឡើយ”។ ប្រសិនបើអង្គជំនុំជម្រះសាលាដំបូងមានប្រព័ន្ធគ្រប់គ្រងសំណុំរឿងរបស់ ក.ស.ច.ស នោះភាគីក៏មានសិទ្ធិមានវាដែរ។ យើងអាចនិយាយបានថា មេធាវីការពារក្តី នឹងស្វាគមន៍ការបញ្ជាក់ឲ្យបានច្បាស់ពីអង្គជំនុំជម្រះសាលាដំបូងទាក់ទិននឹងការណ៍ដែលថាតើបុគ្គលិករបស់ខ្លួនអាចចូលមើលប្រព័ន្ធគ្រប់គ្រងសំណុំរឿងរបស់ ក.ស.ច.ស ឬទេ[១៤]។

---

[១៣] *ពោលគឺ* សហរដ្ឋអាមេរិក អង់គ្លេស និងវេលស៍ កាណាដា និង អាហ្វ្រិកខាងត្បូង។

[១៤] *សូមមើល* លិខិតពីក្រុមមេធាវីការពារក្តីលោក អៀង សារី ផ្ញើជូនលោក ក្រាញ់ តូនី និង លោក Knut Rosandhaug ចុះថ្ងៃទី ៣ ខែ មីនា ឆ្នាំ ២០១១ និងថ្ងៃទី ៩ ខែ ឧសភា ឆ្នាំ ២០១១។ មេធាវីការពារក្តីបានសរសេរលិខិតផ្ញើជូនទៅការិយាល័យរដ្ឋបាលទៅតាមកាលបរិច្ឆេទទាំងពីរខាងលើ “ដើម្បីស្នើសុំព័ត៌មានស្តីពីបុគ្គលិកទាំងអស់ដែលកំពុងបម្រើការងារនៅអង្គជំនុំជម្រះនៃ អ.វ.ត.ក។ ជាពិសេស [មេធាវីការពារក្តី] បានស្នើសុំចង់ដឹងពី៖ **ក.**ឈ្មោះបុគ្គលិក **ខ.**អង្គជំនុំជម្រះដែលពួកគេកំពុងបម្រើ

៩. នៅក្នុងកថាខណ្ឌ១៣ ក.ស.ព អះអាងថា "ការដែលបញ្ចេញឲ្យគេដឹងនូវឯកសារការងារផ្ទៃក្នុងរបស់ ក.ស.ច.ស នាពេលបច្ចុប្បន្ននេះ គឺមិនបានផ្តល់នូវរូបភាពដ៏ត្រឹមត្រូវ អំពីការងារជារួមទាំងមូលរបស់ ក.ស.ច.ស នោះឡើយ (ចំណុចនេះអាចរកបាននៅក្នុងដីកាដំណោះស្រាយ) ..."។ ដីកាដំណោះស្រាយមិនបានឆ្លុះបញ្ចាំងនូវការងារទាំងមូលរបស់ ក.ស.ច.ស ទេ[១៥]។

១០. នៅក្នុងកថាខណ្ឌ១៤ ក.ស.ព អះអាងថា "វិធានដែលប្រឆាំងនឹងការបង្ហាញឲ្យដឹងអំពីលទ្ធផលការងារនៃការស៊ើបសួរនៅក្នុងរឿងក្តីព្រហ្មទណ្ឌ គឺតែត្រូវបានពឹងផ្អែកមិនគ្រាន់តែដោយ ក.ស.ច.ស ប៉ុណ្ណោះទេ ថែមទាំងដោយអ្នកស៊ើបអង្កេតជាតិ និងអន្តរជាតិ និងរដ្ឋអាជ្ញានៅទូទាំងពិភពលោកផងដែរ"។ ការអះអាងនេះគួរឲ្យកត់សម្គាល់ ដោយសារវាមិនមានឯកសារសំអាងដើម្បីគាំទ្រទេ។ ការអះអាងរបស់ ក.ស.ព ដែលថា ប្រសិនបើអង្គជំនុំជម្រះសាលាដំបូងអនុញ្ញាតញត្តិនេះ នោះនឹង "បង្កើតឲ្យទៅជាករណីយុត្តិសាស្ត្រមួយ ... ដែលធ្វើឲ្យខូចដល់សមត្ថភាពរបស់អ្នកស៊ើបអង្កេតដែលត្រូវស្មោះត្រង់នៅក្នុងការសង្កេតរបស់ខ្លួន និងការអនុវត្តទ្រឹស្តីករណីជាច្រើន"

---

ការងារ **គ.**តំណែងដែលពួកគេកំពុងកាន់ និង **ឃ.**តើពួកគធ្លាប់បានកាន់តំណែងមួយនៅក្នុងផ្នែកណាមួយនៅ អ.វ.ត.ក ឬទេ ("ព័ត៌មានដែលបានស្នើសុំ")។ [មេធាវីការពារក្តី] បានធ្វើសំណើសុំនេះដើម្បីជាតម្លាភាព និងបញ្ចៀសនូវទំនាស់ផលប្រយោជន៍សំខាន់ៗ ដែលអាចនាំឲ្យមានបញ្ហាស្តីពីសុច្ចរិតភាព និងភាពមិនលម្អៀងនៅក្នុងកិច្ចដំណើរការនីតិវិធី ...។ ជាពិសេស [មេធាវីការពារក្តី] មានកង្វល់ដែលថាអាចនឹងមានបុគ្គលិកដែលកំពុងបំពេញការងារនៅក្នុងផ្នែកមួយនៃ អ.វ.ត.ក ដែលពីមុនមកធ្លាប់បានបម្រើការងារលើអង្គច្បាប់ និង/ឬ អង្គហេតុ ពោលគឺ ដូចជាការវិភាគជាដើម នៅក្នុងផ្នែកមួយទៀតនៃសាលាក្តីនេះ"។ មេធាវីការពារក្តីមិនបានទទួលការឆ្លើយតបណាមួយចំពោះលិខិតទាំងនោះ ពីការិយាល័យរដ្ឋបាលទេ។ ចាប់តាំងពីថ្ងៃទី ៩ ខែ ឧសភា ឆ្នាំ ២០១១ មក មេធាវីការពារក្តីយល់ថា ចាប់តាំងពីបានទទួលសំណុំរឿង០០២ មក អង្គជំនុំជម្រះសាលាដំបូងកំពុងបង្កើតប្រព័ន្ធគ្រប់គ្រងសំណុំរឿង។ នេះដោយសារតាមការយល់ដឹងរបស់មេធាវីការពារក្តីដែលថា អង្គជំនុំជម្រះសាលាដំបូងអាចទទួលបានសេវាការងារពីបុគ្គលិកដែលធ្លាប់បម្រើការងារ ឬពីអ្នកដែលធ្លាប់បានជួយបង្កើតប្រព័ន្ធគ្រប់គ្រងសំណុំរឿងរបស់ ក.ស.ច.ស។

[១៥] *សូមមើល* ញត្តិ, កថាខណ្ឌ១៧៖ "ឯកសារចំនួន ១.៧៦២ ក្នុងចំណោមឯកសារជាង ៧០.០០០ ដែលត្រូវបានបញ្ចូលទៅក្នុងសំណុំរឿង ត្រូវបានដីកាដំណោះស្រាយលើកយកមកធ្វើជាសំអាង។ មានតែតាមរយៈការដាក់បញ្ចូលប្រព័ន្ធគ្រប់គ្រងសំណុំរឿងរបស់ ក.ស.ច.ស ទៅក្នុងសំណុំរឿងប៉ុណ្ណោះ ទើបភាគីអាចមានលទ្ធភាពយល់អំពីវិធីសាស្ត្ររបស់ ក.ស.ច.ស ក្នុងការវាយតម្លៃសំណុំរឿង*ទាំងមូល* រួមទាំងការពិចារណារបស់ ក.ស.ច.ស ទៅលើលក្ខណៈដាក់បន្ទុក ឬដោះបន្ទុកនៃឯកសារចំនួនប្រមាណ ៦៨.០០០ ដែលបានដាក់បញ្ចូលទៅក្នុងសំណុំរឿង ហើយដែលដីកាដំណោះស្រាយពុំបានលើកយកមកធ្វើជាសំអាង"។

ដែលការអះអាងនេះជាការយល់ខុសចំពោះមុខងាររបស់ចៅក្រមស៊ើបអង្កេត។ នៅក្នុងការអនុវត្ត កិច្ចស៊ើបសួររបស់ខ្លួនដោយសត្យានុម័តដើម្បីស្វែងរកការពិត ក.ស.ច.ស មិនគួរមានរបៀបវារៈការងារ ឬទ្រឹស្តីក្នុងរឿងក្តីណាមួយទេ ។

១១. នៅក្នុងកថាខណ្ឌ១៥ ក.ស.ព អះអាងថា "មកដល់កម្រិតដែលថា ប្រព័ន្ធគ្រប់គ្រងសំណុំរឿងអាចនឹងបង្ហាញឲ្យឃើញច្បាស់អំពីករណីដែលប្រឆាំងនឹងជនជាប់ចោទនោះ ព័ត៌មាននេះមាននៅក្នុងដីកាដំណោះស្រាយ ដីកាសន្និដ្ឋានស្ថាពរ និងនៅក្នុងបញ្ជីរាយឈ្មោះឯកសាររបស់សហព្រះរាជអាជ្ញា អនុលោមតាមវិធាន៨០ នៃវិធានផ្ទៃក្នុងស្រាប់រួចហើយ"។ មេធាវីការពារក្តីចាប់អារម្មណ៍ទៅនឹងភស្តុតាងដោះបន្ទុក រួមទាំងមូលដ្ឋាននៃភស្តុតាងដាក់បន្ទុកទាំងអស់ផងដែរ។ ភស្តុតាងដោះបន្ទុកមិនអាចត្រូវបានរំពឹងថា អាចចេញពីដីកាសន្និដ្ឋានស្ថាពររបស់ ក.ស.ព និងបញ្ជីរាយឈ្មោះឯកសាររបស់ ក.ស.ព អនុលោមតាមវិធាន៨០ នៃវិធានផ្ទៃក្នុងឡើយ។ ដោយការអះអាងថា "ការសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងអំពីពិរុទ្ធភាព ឬភាពស្លូតត្រង់របស់ជនជាប់ចោទ គឺត្រូវបានកម្រិតត្រឹមតែតាមអង្គហេតុដូចដែលមាននៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ និងភស្តុតាងដែលបានដាក់នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងតែប៉ុណ្ណោះ" ក.ស.ព ខកខានមិនបានទទួលស្គាល់ថា ភស្តុតាងដែលបានលើកឡើងនឹងអាចយកចេញបានពី *ក្នុងចំណោមនោះ* ឯកសារទាំងអស់នៅក្នុងសំណុំរឿង[១៦] ដែល ក.ស.ច.ស នឹងយកមកវិភាគ និងកត់ត្រាទុកនៅក្នុងប្រព័ន្ធគ្រប់គ្រងសំណុំរឿងរបស់ខ្លួន។ ការលើកឡើងរបស់ ក.ស.ព ដែលថា "ការបើកឲ្យគ្រប់ភាគីទាំងអស់អាចចូលពិនិត្យមើលឯកសារការងាររបស់ ក.ស.ច.ស បាន គឺមានន័យថា ភស្តុតាងនានាដែលនៅក្នុងសំណុំរឿងអាចត្រូវបានវាយតម្លៃទៅតាមការគិតគូររបស់ ក.ស.ច.ស និងមិនត្រូវបានវាយតម្លៃដោយឯករាជ្យនោះទេ" ត្រូវតែថ្លឹងថ្លែងទៅនឹងផលប្រយោជន៍ដែលបានមកពីការពិនិត្យពិច័យយ៉ាងយកចិត្តទុកដាក់ចំពោះការគិតគូររបស់ ក.ស.ច.ស ដែលបានផ្តល់ឲ្យទៅសម្ភារៈដែលបានដាក់ទៅក្នុងសំណុំរឿង*ទាំងមូល*។ ការពិនិត្យពិច័យនេះត្រូវបានចាំបាច់ត្រូវមាន នៅពេលដែល

---

[១៦] បញ្ជីឯកសារបឋមរបស់ អៀង សារី ដែលមាននៅក្នុងសំណុំរឿងរួចហើយ និងការជូនដំណឹងពីបញ្ជីបឋមនៃឯកសារថ្មីរបស់គាត់ដែលនឹងមកដល់ ដើម្បីដាក់នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ថ្ងៃទី ១ ខែ មេសា ឆ្នាំ ២០១១ ឯកសារ E9/22។

ស្ទម្បីតែបុគ្គលិករបស់ ក.ស.ច.ស រួមទាំងសង្គមស៊ីវិល បានលើកពីបញ្ហាការមិនបំពេញមុខងារ និងកង្វះសុច្ចរិតភាពរបស់ ក.ស.ច.សនោះ[១៧]។

១២. នៅក្នុងកថាខណ្ឌ១៦ ក.ស.ព អះអាងថា "មេធាវីការពារក្ដីបានលើកទឡ្ហីករណ៍ថា បន្ទុកក្នុងការពិនិត្យឡើងវិញលើឯកសារនីមួយៗនៅក្នុងសំណុំរឿង*ចាប់តាំងពីដំបូងមក* គឺវាធំធេងពេក"។ នេះជាការបកស្រាយខុសទាំងស្រុងចំពោះការលើកឡើងរបស់មេធាវីការពារក្ដី ដែលបានសង្កត់ធ្ងន់លើការផ្ដោតអារម្មណ៍ និងការសន្សំពេលវេលាដែលនឹងទទួលបានពីការដាក់បញ្ចូលប្រព័ន្ធគ្រប់គ្រងសំណុំរឿងរបស់ ក.ស.ច.ស ទៅក្នុងសំណុំរឿង[១៨]។ ការអះអាងរបស់ ក.ស.ព ដែលថា "សំណុំរឿងត្រូវបានផ្ដល់ទៅឲ្យមេធាវីការពារក្ដី ជាទម្រង់អេឡិចត្រូនិកតាមរយៈប្រព័ន្ធគ្រប់គ្រងឯកសារ Zylab" ជាការធ្វើឲ្យច្របូកច្របល់ចំពោះវិធាននីតិវិធីផ្សេងៗដែលមានជាធរមាន[១៩]។

១៣. នៅក្នុងកថាខណ្ឌ១៧ ក.ស.ព អះអាងថា មេធាវីការពារក្ដីបាន "ទទួលឯកសារជាង ១.០០០ ឯកសារដែលគាំទ្រដល់ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ នៅក្នុងទម្រង់ជាប្រព័ន្ធគ្រប់គ្រងសំណុំរឿង ដែលជាឯកសារមិនផ្លូវការ"។ ពេលថ្មីៗនេះ មានឯកសារជាង ៧០.០០០ ឯកសារនៅក្នុង

---

[១៧] *សូមមើល ជាឧទាហរណ៍* ចម្លើយរបស់អតីតអ្នកស៊ើបអង្កេតរបស់ ក.ស.ច.ស ឈ្មោះ Stephen Heder *ដែលត្រូវបានដកស្រង់នៅក្នុង* James O'Toole *អ្នកប្រឹក្សាយោបល់កំពុងបន្ដរិះគន់ចៅក្រមនៃសាលាក្ដី (Outgoing Consultant Blasts Tribunal Judges)* កាសែតភ្នំពេញប៉ុស្ដិ៍ ចេញផ្សាយថ្ងៃទី ១៤ ខែ មិថុនា ឆ្នាំ ២០១១៖ ""បើតាមការសម្រេចរបស់ចៅក្រមក្នុងការបិទកិច្ចស៊ើបសួរក្នុងសំណុំរឿង០០៣ ត្រូវបានធ្វើឡើងដោយមានប្រសិទ្ធភាពដោយពុំមានបើកកិច្ចស៊ើបសួរឡើយ ដែលខ្ញុំក៏ដូចជាអ្នកដទៃទៀតជឿថា ជាការមិនសមហេតុផល នៅក្នុងទស្សនៈរបស់បុគ្គលិកអន្តរជាតិក៏ដូចជារូបខ្ញុំផ្ទាល់ដែលមិនមានទំនុកចិត្តចំពោះថ្នាក់ដឹកនាំរស់ខ្លួននោះ និងនៅក្នុងបរិយាកាសដែលត្រូវបានបំពុលដោយការមិនទុកចិត្តគ្នារវាងថ្នាក់ដឹកនាំរបស់ខ្លួនចំពោះអ្វីដែលពេលនេះប្រែក្លាយជាការិយាល័យដែលពុំបានបំពេញការងាររបៀបជាវិជ្ជាជីវៈឲ្យបានត្រឹមត្រូវនោះ ខ្ញុំបានធ្វើការសន្និដ្ឋានថា សេវាផ្នែកប្រឹក្សាយោបល់របស់ខ្ញុំដែលមានប្រយោជន៍អ្វីទៀតហើយ""។ *សូមមើលផងដែរ* James O'Toole *អង្គការក្រៅរដ្ឋាភិបាលមានកង្វល់ពីបញ្ហាសាលាក្ដីខ្មែរក្រហម (NGOs Concerned about KRT)* កាសែតភ្នំពេញប៉ុស្ដិ៍ ចេញផ្សាយថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ ២០១១។ "មានអង្គការក្រៅរដ្ឋាភិបាលក្នុងស្រុកជាង ៣០ បានចូលរួមក្នុងការរិះគន់នូវការដោះស្រាយក្នុងសំណុំរឿង០០៣ និង០០៤ របស់សាលាក្ដីខ្មែរក្រហម ដោយបង្ហាញពីកង្វល់ថា "ភាពមិនលម្អៀង សច្ចៈភាព និងឯករាជភាពរបស់ចៅក្រម អ.វ.ត.ក ត្រូវជួបឧបសគ្គ""។

[១៨] *សូមមើល* ញត្តិ, កថាខណ្ឌ១៦-១៧។

[១៩] វិធាន១០(៤) តម្រូវឲ្យមានការផ្ទុកឯកសារសំណុំរឿងតាមប្រព័ន្ធអេឡិចត្រូនិច មានន័យថា វិធាននេះបានផ្ដល់តួនាទីឲ្យទៅ Zylab។ ម្យ៉ាងវិញទៀត វិធាន៨៦ គឺជាវិធានដែលញត្តិមកយកធ្វើជាសំអាង។

សំណុំរឿង។ វាមិនមែនថាជាការមិនសមរម្យទេដែលសន្មតថា ការបញ្ចេញឲ្យដឹងនូវប្រព័ន្ធគ្រប់គ្រងសំណុំរឿងរបស់ ក.ស.ច.ស ដែលបានចាត់ថ្នាក់ឯកសារប្រហែល ៦៩.០០០ ឯកសារ មិនទាន់ត្រូវបានបញ្ចូលក្នុងប្រព័ន្ធគ្រប់គ្រងសំណុំរឿង ដែលផ្តល់ដោយ ក.ស.ព នឹងបង្កើននូវភាពត្រឹមត្រូវ និងដំណើរការលឿននៃកិច្ចដំណើរការនីតិវិធី។

១៤. នៅក្នុងកថាខណ្ឌ១៨ ក.ស.ព អះអាងថា អង្គជំនុំជម្រះសាលាដំបូងបានសម្រេចរួចហើយលើបញ្ហានេះ ដោយលើកឡើងថា "បន្ទាប់ពីបានចូលមើលឯកសារនៅក្នុងសំណុំរឿង ចាប់តាំងពីចាប់ផ្តើមការស៊ើបសួរ មេធាវីការពារក្តីមិនអាចប្រកាសថាកង្វះពេលវេលា និងផាសុបករណ៍គ្រប់គ្រាន់សម្រាប់ការត្រៀមរៀបចំការការពារក្តីរបស់ខ្លួនឡើយ"[២០]។ ការអាចចូលមើលសំណុំរឿងក្នុងទម្រង់បច្ចុប្បន្ននេះ មិនមែនមានន័យថា មេធាវីការពារក្តីអាចចូលមើលប្រព័ន្ធគ្រប់គ្រងសំណុំរឿងរបស់ ក.ស.ច.ស ទេ។ នេះដោយសារ មេធាវីការពារក្តីបានលើកឡើងថា ប្រព័ន្ធគ្រប់គ្រងសំណុំរឿងជាផ្នែកនៃដំណើរការស៊ើបសួរ ដែលត្រូវតែចាត់ទុកជាផ្នែកសំខាន់នៃសំណុំរឿង។

១៥. នៅក្នុងកថាខណ្ឌ១៩ ក.ស.ព បានសន្និដ្ឋានដោយបញ្ជាក់សាជាថ្មីនូវសំណើរបស់ខ្លួនដែលបានធ្វើនៅក្នុងចម្លើយតប។ ដើម្បីជៀសវាងការលើកឡើងច្រំដែលៗនោះ កថាខណ្ឌនេះមិនចាំបាច់ត្រូវឆ្លើយតបដាច់ដោយឡែកនោះទេ។

សូមចៅក្រមអង្គជំនុំជម្រះសាលាដំបូងទទួលយកសំណើសុំនេះដោយក្តីគោរព។

______________________ ______________________

**អាង ឧត្តម** **Michael G. KARNAVAS**

សហមេធាវីរបស់លោក **អៀង សារី**

ធ្វើនៅភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ថ្ងៃទី **២០** ខែ **មិថុនា** ឆ្នាំ **២០១១**

---

[២០] ចម្លើយតប, លេខ៣០។